# ការណែនាំស្តីពីវិធានការសុវត្ថិភាពប្រឆាំងនឹងកូវីដ-១៩ នារដូវវិស្សមកាលរដូវក្តៅ

## ☐ សង្ខេប

◦ វិស្សមកាលរដូវក្តៅ សម្រាប់ក្រុមគ្រួសារ ឬអង្គភាពខ្នាតតូចដើម្បីជៀសវាងរដូវកាលកំពូលនៅចុងខែកក្កដា និង ដើមខែសីហា, ក្នុងអំឡុងពេលនេះ សូមប្រើប្រាស់ដោយបែងចែករយៈពេលខ្លី លើសពី២ដង

## ☐ វិធានការណ៍

◦ **បែងចែកពេលវេលា និង ទីកន្លែងវិស្សមកាល**

- ពេលវេលាវិស្សមកាលសម្រាប់កន្លែងអាជីវកម្មដែលមានមនុស្ស លើសពី១០០នាក់ គឺត្រូវអនុសាសន៍ឱ្យពង្រីក វិសាលភាព ២សប្តាហ៍ ចាប់ពីសប្តាហ៍ទី៣ នៃខែមិថុនា ដល់សប្តាហ៍ទី៣ នៃខែកញ្ញា

* សមាមាត្រនៃការប្រើប្រាស់វិស្សមកាលក្នុងកំឡុងពេលជាក់លាក់ ស្នើសុំមិនលើសពី១៣%

- ការណែនាំស្តីពីលទ្ធផលនៃការព្យាករណ៍ ជា៥ដំណាក់កាលនៃភាពចង្អៀតណែនណាន់តាន់នៅទីតាំងទេសចរណ៍ និង កន្លែងកំសាន្តសំខាន់ៗ

* គេហទំព័រស្ថាប័នទេសចរណ៍កូរ៉េ "គ្រប់ជ្រុងនៃសាធារណរដ្ឋកូរ៉េ(korean.visitkorea.or.kr)" ៖ ផែនទីធ្វើដំណើរ ដោយសន្តិភាពសមស្របសម្រាប់លក្ខណៈគ្រួសារដោយណែនាំ ២៥កន្លែង ស្របតាមរដូវកាល, សរុបមានចំនួន ១០០កន្លែង

- ការណែនាំល្អិតល្អន់លើផែនទីទេសចរណ៍សុខភាព ដែលអ្នកអាចទៅជាមួយគ្រួសាររបស់អ្នក ផ្លូវដើរទេសចរណ៍, ការអភិរក្សព្រៃ។ល។

◦ **លក្ខណៈពិសេសនៃតំបន់ទេសចរណ៍សំខាន់ៗ បង្កើតច្បាប់ការពារការរីករាលដាលត្រឹមត្រូវ**

- ឆ្នេរសមុទ្រ : អនុវត្តន៍ច្បាប់ពង្រីកប្រព័ន្ធការកក់ទុកជាមុនចំនួន៥០(១៣ → ៥០)

·ព័ត៌មានអំពីការប្រើភ្លើងចរាចរណ៍ដើម្បីបង្ហាញកម្រិតពីភាពកកស្ទះនៃឆ្នេរសមុទ្រទាំងអស់, អនុវត្តតាមឆ្នេរដែលមាន អ្នកទេសចរណ៍ច្រើន ហើយទុកឆ័ត្រការពារកម្តៅថ្ងៃអោយនៅដាច់ពីគ្នា។

- កន្លែងកម្សាន្តដូចជាឧទ្យានទឹក : ការកំណត់ចំនួនមនុស្សជាក់លាក់ នៃការប្រើប្រាស់បន្ទប់ផ្លាស់ប្តូរសំលៀកបំពាក់

- ការកក់កន្លែងស្នាក់នៅ មានកំណត់ត្រឹម ៤នាក់, ក្នុងករណីសមាជិកគ្រួសារ ៤នាក់

◦ **នៅពេលវិស្សមកាលបើមានការសង្ស័យរោគសញ្ញាកូវីដ-១៩ ជាមូលដ្ឋានត្រូវធ្វើតេស្តរោគវិនិច្ឆ័យ យ៉ាងឆាប់រហ័ស**

- ការណែនាំស្តីអំពីម៉ោងធ្វើការ និងទីតាំងគ្លីនិកពិនិត្យ និងមណ្ឌលពិនិត្យបណ្តោះអាសន្ន

- ដំឡើងបន្ថែមដំឡើងគ្លីនិកពិនិត្យបណ្តោះអាសន្ន·ចល័ត នៅតំបន់ទេសចរណ៍ និងកន្លែងវិស្សមកាល, គ្លីនិកពិនិត្យ ចល័ត, ឧបករណ៍សំរាប់ពិនិត្យដោយខ្លួនឯង(kit) នឹងនឹងត្រូវបានផ្តល់ជូននៅតាមឱសថស្ថាន និងហាងងាយស្រួល (ហាងលក់២៤ម៉ោង)ដែលនៅក្បែរៗ។

**<បកប្រែដោយមជ្ឈមណ្ឌលប្រឹក្សាតាមទូរស័ព្ទដានូរី ១៥៧៧-១៣៦៦>**

## < ព័ត៌មានលម្អិតពីវិធានការការពារសម្រាប់កន្លែងនីមួយៗ>

| ការចាត់កន្លែង | វិធានការការពារលម្អិតសម្រាប់កន្លែងនីមួយៗ |
|---|---|
| 1. តំបន់វិស្សមកាល និងកន្លែងកម្សាន្តផ្សេងៗ | |
| ① ឆ្នេរសមុទ្រ | • ការជូនដំណឹងតាមពេលវេលានៃការកកស្ទះ(ប្រព័ន្ធភ្លើងចរាចរណ៍កកស្ទះ) តាមឆ្នេរទូទាំងប្រទេស;<br>កកស្ទះ(ក្រហម), ព្រួយបារម្ភកកស្ទះ(លឿង), សមរម្យ(ខៀវ)<br>• បិទស្លាកសីតុណ្ហភាពរាងកាយ, ពិនិត្យមើលកំដៅហើយពាក់ខ្សែដៃសុវត្ថិភាព<br>• ប្រព័ន្ធកក់ទុកមុន(៥០ទីតាំងទូទាំងប្រទេស), ប្រព័ន្ធបែងចែកទីតាំងសម្រាប់តំបន់នីមួយៗនៃឆ្នេរខ្សាច់ពណ៌ស, ការជ្រើសរើស និងការផ្សព្វផ្សាយឆ្នេរខ្សាច់ដែលនៅដាច់ឆ្ងាយ<br>• ការហាមមិនអោយការផឹក និងបរិភោគនៅពេលយប់ |
| ② កន្លែងកម្សាន និង ឧទ្យានទឹក ផ្សេងៗ | • ប្រកាស និង ណែនាំចំនួនអ្នកប្រើប្រាស់, បង្ហាញពីចម្ងាយរវាងកន្លែងរង់ចាំ<br>• កំណត់ចំនួនមនុស្សប្រើប្រាស់ទីធ្លាសាធារណៈ, ប្រើប្រាស់ឧទ្ទកាល័យកន្លែងឃ្លាតឆ្ងាយពីគ្នាមួយកន្លែង<br>• ការប្រើប្រាស់កន្លែងសំរាកខាងក្រៅ |
| ③ ជ្រលងភ្នំ•ទន្លេ | • ការដំឡើងតង់, ការក្រាលកន្ទេលជាដើម ត្រូវរក្សាគម្លាតពីគ្នា(យ៉ាងហោចណាស់ ២ម៉ែត្រ)<br>• ការគ្រប់គ្រងចំនួនមនុស្សដែលប្រើប្រាស់កន្លែងសាធារណៈ និង កន្លែងប្រើប្រាស់ច្រើនប្រភេទ |
| ④ តំបន់ទេសចរណ៍សំខាន់ៗ | • ផ្តល់អនុសាសន៍ឱ្យកំណត់ចំនួនអ្នកដំណើរ ជិះរថយន្តខ្សែកាប(ក្រោម ៥0%)<br>• សម្គាល់ការកំណត់ចំនួនភ្ញៀវ និងរក្សាគម្លាតចម្ងាយ នៅតាមការិយាល័យលក់សំបុត្រ។ល។<br>• ប្រតិបត្តិការ ដោយផ្លូវចេញចូលតែមួយ<br>• ណែនាំឱ្យឈប់ប្រើប្រាស់ចំណតឡានក្រុងធំៗ និង ហាមចតនៅក្បែរតំបន់ទេសចរណ៍ |
| ⑤ ឧទ្យានជាតិនានា | • ផ្តល់អនុសាសន៍ឱ្យកំណត់ចំនួនអ្នកជិះរថយន្តខ្សែកាបឱ្យតិចជាង ៥0%<br>• ជៀសវាងការធ្វើដំណើរកំសាន្តជាក្រុម, ថែរក្សា•គ្រប់គ្រងដង់ស៊ីតេត្រឹមត្រូវ កន្លែងក្នុងអាគារ |
| ⑥ កន្លែងសំខាន់ៗផ្សេងៗ | • (សួនសត្វ) ជូនដំណឹង•ការកំណត់ចំនួនភ្ញៀវទេសចរ ប្រើកន្លែងទស្សនាក្នុងអាគារ,<br>• (វិទ្យាស្ថានជាតិបរិស្ថានវិទ្យា) កំណត់ចំនួនភ្ញៀវទេសចរនា កន្លែងតាំងពិព័រណ៍ក្នុងអាគារ, ណែនាំការប្រើប្រាស់កន្លែងខាងក្រៅអាគារ ការរៀបចំព្រឹត្តិការណ៍ ដោយប្រើកន្លែងខាងក្រៅអាគារ។ល។<br>•(វិទ្យាស្ថានធនធានជីវសាស្ត្រ) ការកក់តាមអ៊ីនធឺណិត, មិនលើសពី១០០នាក់ ក្នុងមួយម៉ោង, អាចបិទសាលតាំងពិព័រណ៍ប្រសិនបើចាំបាច់ |
| ⑦ ពិធីបុណ្យរដូវក្តៅ | • ព្យាយាមមិនជួបមុខផ្ទាល់ តាមដែលអាចធ្វើទៅបាន<br>• ធ្វើពិធីអបអរសាទរជួបផ្ទាល់មុខ ប្រតិបត្តិការនៅខាងក្រៅ, ណែនាំការកក់ទិញតាមអ៊ិនធឺណេតជាមុន, កំណត់អ្នកចូលរួម, ច្រកចេញ•ច្រកចូលដាច់ដោយឡែក, ធ្វើដំណើរក្នុងទិសដៅតែមួយ, ហាមធ្វើសកម្មភាព និងការទទួលទានអាហារជាក្រុម។ |
| 2. កន្លែងស្នាក់នៅ•កន្លែងកំសាន្ត•ការធ្វើដំណើរ | |
| ① កន្លែងស្នាក់នៅ | • កំណត់នៃការកក់មិនលើសពី ៥នាក់ឡើង(សមាជិកគ្រួសារផ្ទាល់ ៨នាក់) |
| ② កន្លែងកំសាន្តនានា | • ការអនុលោមតាមម៉ោងធ្វើការ, ការកំណត់ចំនួនភ្ញៀវប្រើប្រាស់, ការគ្រប់គ្រងបញ្ជីភ្ញៀវចេញចូល, ការត្រួតពិនិត្យរោគសញ្ញា ត្រួតពិនិត្យកំដៅ(បុគ្គលិក)ដោយយ៉ាងសកម្ម |
| ③ កន្លែងធ្វើដំណើរ | • ស្ថានីយរថភ្លើង, ស្ថានីយ, អាកាសយានដ្ឋាន : ដំឡើងកាមេរ៉ាថតកំដៅ, ការបំបែកភ្ញៀវប្រើប្រាស់ផ្លូវដោយឡែក, ការឆែកនីតិវិធីជិះដោយខ្លួនឯង មិនជួបមុខផ្ទាល់, ថ្នាំលាងដៃសំលាប់មេរោគ ។ល។<br>• ស្ថានីយសំរាក :ភោជនីយដ្ឋាន•តំឡើងកញ្ចក់ថ្លាសំរាប់តុកាហ្វេ, ការចុះបញ្ជីឈ្មោះចេញចូល, ការបំបែកភ្ញៀវប្រើ |

| | |
|---|---|
| | ប្រាស់**ផ្លូវដោយឡែក,** ផ្គត់ផ្គង់ថ្នាំលាងដៃសំលាប់មេរោគ, **ការស្នាក់នៅក្នុងពេលវេលាតិចបំផុត។ល។** |
| **3. កន្លែងវិស្សមកាល ទីប្រជុំជន• ទស្សនាកីឡាខាងក្រៅ** | |
| ① **សារមន្ទីរ• វិចិត្រសាលសិល្បៈ** | • ប្រកាសចំនួនភ្ញៀវប្រើប្រាស់ និង ប្រតិបត្តិការតាម**ប្រព័ន្ធកក់ទុកជាមុន** |
| ② **សាលប្រគុំតន្ត្រី** | • តាមដែលអាចធ្វើទៅបាន ណែនាំឱ្យ**កក់ជាមុនតាមអ៊ីនធឺណិត**, **ភ្ញៀវទស្សនាអាចចូលពេលវេលាខុសគ្នា**<br>• ការបែងចែកពហុកន្លែងប្រើប្រាស់ច្រើនប្រភេទ, **ហាមនាំយកអាហារចូលនិង ហាមបរិភោគអាហារ**<br>• ដើម្បីណែនាំអោយមានការរក្សាចម្ងាយ វិធានការណ៍នៃ**បិទស្លាកលើកំរាល។ល។**<br>• ការណែនាំឱ្យប្រើបន្ទប់ជក់បារីខាងក្រៅ |
| ③ **រោងភាពយន្ត** | • ត្រូវពាក់ម៉ាស, **បើអាចធ្វើបាន ណែនាំឱ្យកក់ទិញមុនតាមអ៊ីនធឺណិត**<br>• ភ្ញៀវទស្សនាអាចចូលពេលវេលាខុសគ្នា |
| ④ **បេហ្សប័ល• បាល់ទាត់។ល។** | • ណែនាំ**ការកក់ទិញមុនតាមអ៊ិនធឺណេត**, សូមប្រើរបស់របរផ្ទាល់ខ្លួនដូចជាឧបករណ៍លើកទឹកចិត្ត<br>• **រៀបចំទីកន្លែងទំនេរឯករាជ្យលំទូលាយ សម្រាប់អ្នកប្រើប្រាស់មានរោគសញ្ញារង់ចាំ**<br>• **ជៀសវាងធ្វើសកម្មភាព និង ព្រឹត្តិការណ៍ដែលនាំឱ្យមានទំនាក់ទំនង**រវាងមនុស្សនិងមនុស្ស |

**<បកប្រែដោយមជ្ឈមណ្ឌលប្រឹក្សាតាមទូរស័ព្ទដានូរី ១៥៧៧-១៣៦៦>**